# ផ្ទះប៉ិត

ជាប្រភេទផ្ទះមានដំបូលផ្តុំឡើងដោយផ្ទាំង៤ ដែលមានជម្រាលស្មើគ្នា ហើយពុំមានហោជាងនៅផ្នែកណាមួយនៃដំបូលឡើយ។ ជាទូទៅបើមើលលើប្លង់ផ្ទះប៉ិតដែលមានតែមួយខ្នង់ ឃើញថាទ្វារមិននៅលើជ្រុងខ្ទីទេ គឺនៅលើជ្រុងវែង។ គេអាចពង្រីកផ្ទះប៉ិតសាមញ្ញឲ្យមានរូបរាងច្រើនបែបយ៉ាង។ ផ្ទះប៉ិត ជាធម្មតាមានពីរខ្នង ប៉ុន្តែជួនកាលអាចមានច្រើនជាងនោះរហូតដល់ប្រាំខ្នងក៏មាន។ បើតាមវចនានុក្រមខ្មែរពាក្យថា "ប៉ិត" មានន័យថា ជាឈ្មោះផ្ទះមួយបែប ផ្សេងពីផ្ទះកន្តាំង និងផ្ទះរោងដោល គឺមានសណ្ឋានដូចគេប៉ិតត្រង់ចុងមេដំបូលទាំងពីរខាងដែលគេឱ្យឈ្មោះថា "ផ្ទះប៉ិត" ។

នៅសម័យដើមសំណង់ផ្ទះប៉ិត ពិតជាល្អប្រណិតណាស់ រួមទាំងគ្រឿងតុបតែងលម្អក្នុងផ្ទះ ដោយម្ចាស់ផ្ទះសុទ្ធតែអ្នកមានទ្រព្យសម្បត្តិ និងឋានៈខ្ពង់ខ្ពស់ជាសាងសង់ ឧទាហរណ៍ លោក ឧកញ៉ា ពិនិត្យ ភឹង សង់ផ្ទះប៉ិតនៅខេត្តបាត់ដំបង និងជង្ហោ ស៊ុន ហ៊ី សង់ផ្ទះប៉ិតនៅខេត្តក្រចេះជាដើម។ មកដល់សព្វថ្ងៃនេះ យើងឃើញមាននៅសល់សំណង់ផ្ទះប៉ិតខ្លះដែរ ដែលស្ថិតនៅតាមបណ្តាខេត្តនានានៅក្នុងស្រុកខ្មែរដូចជានៅខេត្តបាត់ដំបង ខេត្តក្រចេះ ខេត្តព្រៃវែង ខេត្ត កំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តកណ្តាលជាដើម។ តែសំណង់ទាំងនោះខ្លះនៅល្អរឹងមាំដោយការថែរក្សាដិតដល់ពីម្ចាស់ផ្ទះ ខ្លះទៀតមានសភាពទ្រុតទ្រោមខ្លាំង ដោយសារអាយុកាលនៃឈើ ពីព្រោះសំណង់ឈើងាយ នឹងទទួលរងការពុកផុយណាស់ ។ ម្យ៉ាងទៀត សំណង់ផ្ទះប៉ិតខ្លះត្រូវម្ចាស់រុះរើ ដោយស្ថានភាពផ្ទះទ្រុតទ្រោម ឬអាចម្ចាស់ផ្ទះមានលទ្ធភាព និងបំណងចង់សាងសង់ផ្ទះបែបរចនាបថបច្ចុប្បន្ន៕

អត្ថបទដោយ៖ លោក ថាន់ មនោមយិទ្ធិ

AMS
Khmer Civilization



ទម្រង់ផ្ទះប៉ិត



ផ្ទះប៉ិតរុះរើដោយសង់បែបរចនាបថសម័យថ្មី

អត្ថបទដោយ៖ លោក ថាន់ មនោមយិទ្ធិ